ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសឹង្ហបុរី

លេខ: 85 សកសប

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**<u>កម្មវត្ថុ:</u>** *របាយការណ៍ប្រចាំខែ មីនា ឆ្នាំ២០១២ ស្តីអំពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្មអមស្ថានទូតកម្ពុជាប្រចាំសឹង្ហបុរី ។*

*តបតាមកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមដាក់ជូន* **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** *មេត្តាជ្រាបនូវរបាយការណ៍ស្តីអំពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្ម ក្នុងខែ មីនា ឆ្នាំ ២០១២ មានដូចខាងក្រោម:*

## *<u>១. ពាណិជ្ជកម្មទ្វេភាគី កម្ពុជា -សឹង្ហបុរី</u>*

*តួលេខនៃជញ្ជីងពាណិជ្ជកម្មរវាង កម្ពុជា-សឹង្ហបុរី ក្នុងរយ:ពេល ០២ ខែ ដើមឆ្នាំ ២០១២ មានចំនួន ២៦១.២៧១.០០០ដុល្លារសឹង្ហបុរី ការនាំចូលពីប្រទេសកម្ពុជាមានចំនួន ៥១.០៦៥.០០០ដុល្លារសឹង្ហបុរី ដែលផលិតផលចំបងរួមមាន ថ្ម ខ្សាច់ និងគ្រួសល្អិត គ្រឿងអលង្ការ មាសប្រាក់ ឧបករណ៍ធ្វើឲ្យមានសីតុណ្ហភាព* (Thermionic) *គ្រឿងបន្លាស់ និងឧបករណ៍អេឡិចត្រូនិក គ្រឿងបន្ទាប់បន្សំវាយនភណ្ឌ សំលៀកបំពាក់ បារី ថ្នាំជក់ ស្បែកជើង និងអង្ករ។ រីឯការនាំចេញទៅប្រទេសកម្ពុជាវិញមានចំនួន ២១០.២០៦.០០០ដុល្លារសឹង្ហបុរី ដែលផលិតផលចំបង រួមមានប្រេងឥន្ធន: ស្រា និងភេសជ្ជ: ឧបករណ៍ និងគ្រឿងបន្លាស់ទូរគមនាគមន៍។ល។*

*តារាងសង្ខេបនៃពាណិជ្ជកម្មរបស់សឹង្ហបុរីជាមួយកម្ពុជា ២ ខែ ដើមឆ្នាំ ឆ្នាំ ២០១២*

| | 2011 | Feb 2012 |
|---|---|---|
| Total | 1,379,017 | 261,271 |
| Imports | 238,928 | 51,065 |
| Exports | 1,140,089 | 210,206 |

*ប្រភព: សហគ្រាសអន្តរជាតិសឹង្ហបុរី (IE Singapore) ចំនួនគិតជា ពាន់ដុល្លារសឹង្ហបុរី*

## *<u>២. សកម្មភាពការងារ:</u>*

*-កាលពីថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ បានចូលរួមស្តាប់* SMU Presidential Distinguished Lecturer Series *ស្តីពីអត្ថន័យនៃសៀវភៅដែលមានចំណងជើង* Run of the Red Queen *ដែលធ្វើបទឧទ្ទេសនាមដោយលោក* Dan Breznitz *ជាអ្នកនិពន្ធសៀវភៅ។*



Address : 400 Orchard Road, #10-03/04, Orchard Towers, Singapore 238875
Website : http://home.pacific.net.sg/~recambodia.sg
Tel: (65) 63419785 , Fax: (65) 63419201
E-mail: cambodiaembasy@pacific.net.sg

-កាលពីថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយលោកស្រី Tou Lie LIM, តំណាងក្រុមហ៊ុន Medical Asia Group ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ដែលមានបំណងស្វែងយល់ពីបែបបទ លក្ខខ័ណ្ឌដើម្បីបង្កើតការិយាល័យតំណាងរបស់ខ្លួននៅកម្ពុជា ក្នុងការផ្តល់សេវាកម្មពិគ្រោះយោបល់ និង ព្យាបាលសុខភាព។

-កាលពីថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២ បានចូលរួមកម្មវិធីវេទិកាពាណិជ្ជកម្មទួរគី-សិង្ហបុរី ដែលរៀបចំដោយស្ថានទូតទួរគីប្រចាំនៅសិង្ហបុរី រួមជាមួយសហព័ន្ធពាណិជ្ជកម្មសិង្ហបុរី ក្រោមអធិបតីភាព ឯកឧត្តម Ali Babacan ឧបនាយករដ្ឋមន្ត្រីនៃប្រទេសទួរគី។

-កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Etienne Chenevier, ជាដៃគូរ និង នាយកប្រចាំតំបន់អាស៊ីនៃក្រុមហ៊ុន CityStar Private Equity Asia Pte Ltd & CityStar Capital Asia Pte Ltd ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ស្តីពីការស្វែងរកដៃគូវិនិយោគពីប្រទេសសិង្ហបុរីលើវិស័យអចលនៈទ្រព្យនៅកម្ពុជា។

-កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Subra M Suppiah, Advocate & Solicitor, ការិយាល័យច្បាប់ Subra TT Law LCC ដែលមានទីតាំងនៅប្រទេសសិង្ហបុរី មានបំណងស្វែងយល់ពីសក្តានុពល បរិយាកាសធ្វើពាណិជ្ជកម្ម វិនិយោគ ប្រព័ន្ធច្បាប់នៅកម្ពុជា និងការីកចំរើនវិស័យទេសចរណ៍ ហើយលោកក៏បានជម្រាបពីបំណងក្នុងការបង្កើតទីភ្នាក់ងារទេសចរណ៍នៅប្រទេសកម្ពុជាផងដែរ។

-កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Alan Tan Wing Wton នាយកផ្នែកពាណិជ្ជកម្មសាកលទទួលបន្ទុកប្រទេសអាស៊ាន និងអាស៊ីខាងត្បូង នៃសហព័ន្ធពាណិជ្ជកម្មសិង្ហបុរី ស្តីពីការរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់ប្រទេសកម្ពុជានាខែវិច្ឆិកាខាងមុខ និង លទ្ធភាពក្នុងការពង្រីងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសិង្ហបុរី ក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងការជំរុញវិស័យពាណិជ្ជកម្ម និង វិនិយោគនៅកម្ពុជា។

-កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ Dr. Johnny Goh ប្រធាន Singapore Recreation Club និងលោក Victor Chng ដៃគូ នៃក្រុមហ៊ុន Starion Capital Limited ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ស្តីពីការវិនិយោគលើវិស័យអចលនៈទ្រព្យនៅកម្ពុជា។

-កាលពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Jahabar Sathik ម្ចាស់ក្រុមហ៊ុន Earth Wealth Enterprises ដែលមានទីតាំងនៅប្រទេសសិង្ហបុរី មានបំណងស្វែងរកដៃគូនៅក្នុងស្រុកដែលមានអាជ្ញាប័ណ្ណលើការរុករករ៉ែដែក និង ម៉ង់ហ្កាណេស ដើម្បីបង្កើតជាក្រុមហ៊ុនបន្ទាក់ទុនរួមគ្នា (Joint Venture) វិនិយោគលើការរុករករ៉ែនៅកម្ពុជា។

-កាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ បានរួមដំណើរជាមួយលោកជំទាវឯកអគ្គរាជទូត ដើម្បីចូលរួមស្តាប់បទឧទ្ទេសនាមនៃការចុះបញ្ជីពាណិជ្ជកម្មរបស់អាជ្ញាធរនិយ័តកម្មគណនេយ្យ និងសាជីវកម្ម (Accounting & Corporate Regulatory Authority)។

-កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ បានរួមដំណើរជាមួយលោកជំទាវឯកអគ្គរាជទូត ចូលរួមពិធីបណ្តាញនៃសប្តាហ៍ថាមពលអន្តរជាតិសិង្ហបុរី (Singapore International Energy Week Networking Reception) ដែលរៀបចំឡើងដោយអាជ្ញាធរទីផ្សារថាមពល (EMA)របស់សិង្ហបុរី។

-កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ជួបពិភាក្សាការងារជាមួយ លោក Thomas CHOO នាយកប្រតិបត្តិនៃក្រុមហ៊ុន Thomas Carlington & Associates Pte Ltd ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មប្រឹក្សាយោបល់មានទីតាំងនៅសឹង្ហបូរី ស្តីពីការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេសការបង្កើតការិយាល័យឥណទាន (Credit Bureau) និងការវិនិយោគទៅលើវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាដំណឹង ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

សឹង្ហបូរី, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២

អ្នកធ្វើរបាយការណ៍

អនុព័ន្ធពាណិជ្ជកម្ម

ម៉ៅ សាកល

**បានឃើញ និង ឯកភាព**

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

សឹង្ហបូរី, ថ្ងៃទី 05 ខែ មេសា ឆ្នាំ ២០១២

**ឯកអគ្គរាជទូត**

**ស៊ិន សិរី**

ចម្លងជូន:

-ក្រសួងពាណិជ្ជកម្ម

-ឯកសារ - កាលប្បវត្តិ

**SUMMARY OF SINGAPORE'S TRADE WITH CAMBODIA**
**Current Period: 2012 February**
**Value ($K)**

| | IMPORTS | EXPORTS | DOMESTIC EXPORTS | TOTAL TRADE |
|---|---|---|---|---|
| | ($) | ($) | ($) | ($) |
| 2008 | 164,382 | 733,740 | 330,855 | 898,122 |
| 2009 | 614,072 | 1,038,427 | 459,504 | 1,652,499 |
| 2010 | 217,391 | 3,000,324 | 539,322 | 3,217,716 |
| 2011 | 238,928 | 1,140,089 | 559,501 | 1,379,017 |
| 2012 / Feb | 51,065 | 210,206 | 93,622 | 261,271 |

Source: IE Singapore

**SINGAPORE'S IMPORTS FOR CAMBODIA**
**Current Period: 2012 February**
**Value ($K)**

| | | 2011 | 2012 / Feb |
|---|---|---|---|
| COUNTRY | TOTAL | 238,928 | 51,065 |
| TOP | SITC TOTAL | 186,789 | 50,886 |
| 273 | STONE SAND & GRAVEL | 115,003 | 26,932 |
| 897 | JEWELLERY, GOLDSMITHS' & SILVERSMITHS' WARES, & OTHER ARTICLES OF PRECIOUS OR SEMIPRECIOUS MATERIALS NES | 40,772 | 14,739 |
| 776 | THERMIONIC, COLD CATHODE OR PHOTOCATHODE VALVES & TUBES; DIODES, TRANSISTORS; PHOTOSENSITIVE SEMICONDUCTOR DEVICES; LIGHTEMITTING DIODES; MOUNTED PIEZOELECTRIC CRYSTALS; ELECTRONIC INTEGRATED CIRCUITS & MICROASSEMBLES; PARTS THEREOF | 228 | 1,770 |
| 845 | ARTICLES OF APPAREL, OF TEXTILE FABRICS, WHETHER OR NOT KNITTED OR CROCHETED NES | 6,546 | 1,404 |
| 122 | TOBACCO, MANUFACTURED (WHETHER OR NOT CONTAINING TOBACCO SUBSTITUTES) | 6,285 | 1,224 |
| 851 | FOOTWEAR | 6,684 | 821 |
| 42 | RICE | 483 | 756 |
| 844 | WOMEN'S OR GIRLS' COATS, CAPES, JACKETS, SUITS, TROUSERS, SHORTS, SHIRTS, DRESSES & SKIRTS, UNDERWEAR, NIGHTWEAR & SIMILAR ARTICLES OF TEXTILE FABRICS, KNITTED OR CROCHETED EXCL SUBGROUP 845.2 | 1,574 | 531 |
| 773 | EQUIPMENT FOR DISTRIBUTING ELECTRICITY NES | 52 | 459 |
| 841 | MEN'S OR BOYS' COATS, CAPES, JACKETS, SUITS, BLAZERS, TROUSERS, SHORTS, SHIRTS, UNDERWEAR, NIGHTWEAR & SIMILAR ARTICLES OF TEXTILE FABRICS, NOT KNITTED OR CROCHETED EXCL SUBGROUP 845.2 | 2,027 | 420 |

Source: IE Singapore

## SINGAPORE'S EXPORTS FOR CAMBODIA

**Current Period: 2012 February**

**Value ($K)**

| | | 2011 | 2012 / Feb |
|---|---|---|---|
| | COUNTRY TOTAL | 1,140,089 | 210,206 |
| | TOP SITC TOTAL | 962,641 | 186,524 |
| 334 | PETROLEUM OILS & OILS OBTAINED FROM BITUMINOUS MINERALS EXCL CRUDE; PREPARATIONS NES, CONTAINING BY WEIGHT 70% OR MORE OF PETROLEUM OILS OR OF OILS OBTAINED FROM BITUMINOUS MINERALS, THESE OILS BEING THE BASIC CONSTITUENTS OF THE PREPARATIONS; WASTE OILS | 641,741 | 126,882 |
| 112 | ALCOHOLIC BEVERAGES | 79,629 | 17,823 |
| 764 | TELECOMMUNICATIONS EQUIPMENT NES, PARTS NES, & ACCESSORIES OF APPARATUS FALLING WITHIN SITC 76 | 28,406 | 6,005 |
| 759 | PARTS & ACCESSORIES EXCL COVERS, CARRYING CASES & THE LIKE, SUITABLE FOR USE SOLELY OR PRINCIPALLY WITH MACHINES FALLING WITHIN GROUPS 751 & 752 | 28,101 | 4,914 |
| 785 | MOTOR CYCLES INCL MOPEDS & CYCLES, MOTORIZED & NON-MOTIRIZED; INVALID CARRIAGES | 29,327 | 4,030 |
| 741 | HEATING & COOLING EQUIPMENT & PARTS THEREOF NES | 21,591 | 3,417 |
| 752 | AUTOMATIC DATA-PROCESSING MACHINES & UNITS THEREOF; MAGNETIC OR OPTICAL READERS, MACHINES FOR TRANSCRIBING DATA ONTO DATA MEDIA IN CODED FORM & MACHINES FOR PROCESSING SUCH DATA NES | 36,530 | 3,383 |
| 122 | TOBACCO, MANUFACTURED (WHETHER OR NOT CONTAINING TOBACCO SUBSTITUTES) | 17,323 | 2,798 |
| 745 | NON-ELECTRICAL MACHINERY, TOOLS & MECHANICAL APPARATUS & PARTS THEREOF NES | 5,386 | 2,579 |

| | | | |
|---|---|---|---|
| 761 | MONITORS & PROJECTORS, NOT INCORPORATING TELEVISION RECEPTION APPARATUS; RECEPTION APPARATUS FOR TELEVISION, WHETHER OR NOT INCORPORATING RADIO-BROADCAST RECEIVERS OR SOUND OR VIDEO RECORDING OR REPRODUCING APPARATUS | 9,205 | 2,359 |

Source: IE Singapore